ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ: ៥៦៦ "វ"
-ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ១៩៤៣
ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០
-ស៊ើបសួរលេខ ៤៧០៥
ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០
-ជំនុំជម្រះលេខ ៤៥៧៦
ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

តាមនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២២ វេលាម៉ោង ៨និង ០០នាទីព្រឹក នៅសាលសវនាការទី៥ ដោយមានសមាសភាព ៖

ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៤៣ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] ហួគង់ ភេទប្រុស អាយុ ៦៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ពាណិជ្ជករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ធំ មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះលេខ ១A ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឡាក់"ស"ម្តាយឈ្មោះ [redacted] ឆ្លងខេង "ស" ប្រពន្ធឈ្មោះ [redacted] សុខឡេង (លែងលះ) មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។

ពីបទ **រំលោភ** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីគាង ភេទស្រី អាយុ ៥៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ អាជីវករ មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះលេខ ២ ផ្លូវលេខ ១១១អា ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-លោកស្រី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-លោក [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-លោក [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-លោកស្រី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-លោកស្រី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

អត្ថហេតុនៃរឿងមានដូចតទៅ

-កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ឈ្មោះ [redacted] លីគាង បានប្តឹងឈ្មោះ [redacted] ហួគង់។ ឈ្មោះ [redacted] ហួគង់ បានហៅឈ្មោះ [redacted] លីគាង ទិញដីរបស់គាត់ក្នុងភាគហ៊ុន នៃក្រុមហ៊ុនហួលីត្រឺងចំនួន ពាក់កណ្តាល

ក្នុងតម្លៃ៣0,000 (បីម៉ឺន) ដុល្លារអាមេរិក ឈ្មោះ[redacted]លីគាង ក៏យល់ព្រមទិញដីនេះដោយពុំបានទៅមើលទីតាំងដី ឬធ្វើឯកសារផ្ទេរសិទ្ធិទាំងអស់ដោយសំអាងថា ឈ្មោះ[redacted] ហួគង់ ជាពួបង្កើតរបស់ឈ្មោះ[redacted] លីគាង មិនកុហកបោកប្រាស់ឈ្មោះ[redacted] លីគាង នោះទេ។ នៅពេលឈ្មោះ[redacted] លីគាង បានប្រគល់ប្រាក់ទៅឱ្យឈ្មោះ[redacted] ហួគង់ រួចមកឈ្មោះ[redacted] ហួគង់ ក៏បានសរសេរលិខិតមួយសន្លឹកជាអក្សរចិន និងចុះហត្ថលេខារបស់គាត់ប្រគល់ឱ្យឈ្មោះ[redacted]លីគាង បញ្ជាក់ថា ឈ្មោះ[redacted] ហួគង់ លក់ដីឱ្យឈ្មោះ[redacted]លីគាង ចំនួន ៣ហិកតា តម្លៃ ៣0,000 (បីម៉ឺន)ដុល្លារអាមេរិក និងលក់ឱ្យទៅបងស្រីឈ្មោះIVEN ចំនួន ៣ហិកតា តម្លៃ ៣0,000 (បីម៉ឺន)ដុល្លារអាមេរិក និងលក់ឱ្យទៅឈ្មោះ ប៉ោជ្ជ ចំនួន ៣ហិចតា សរុបចំនួន ៩ហិកតា ចាប់តាំងពីថ្ងៃលក់ដីឱ្យឈ្មោះ[redacted] លីគាង រួចមកឈ្មោះ[redacted]លីគាង មិនដែលដឹងថាឈ្មោះ[redacted] ហួគង់ គ្មានដីក្នុងចំណែកភាគហ៊ុន ហួលីត្រឹង ឈ្មោះ[redacted] លីគាង ទើបតែដឹងនៅពេលក្រុមហ៊ុន ហួលី ត្រឹង លក់ដីឱ្យក្នុងឆ្នាំ២០១៨ ឈ្មោះ[redacted]លីគាង បានស្នើសុំឱ្យឈ្មោះ[redacted] ហួគង់ សងប្រាក់ថ្លៃទិញដីតាមទីផ្សារដីដែលមានទីតាំងស្ថិតនៅសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ មកឱ្យឈ្មោះ[redacted]លីគាង វិញ តែឈ្មោះ[redacted] ហួគង់ មិនព្រមចេះតែគេចវេសរហូត។

-បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២0 របស់ឈ្មោះ[redacted] លីគាង។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៦៧0 **អ.ឃ.ឈ** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២0២0 របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ៤៤២0 អ.ឃ.ឈ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២0២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៩៧៤ "ដ"ដ.ដ ចុះថ្ងៃទី ២0 ខែ ធ្នូ ឆ្នាំ ២0២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]ហួគង់ បានឆ្លើយថា៖ ខ្ញុំសូមបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការ និងសូមបដិសេធពាក្យបណ្តឹងចោទប្រកាន់របស់ឈ្មោះ[redacted] លីគាង ចោលទាំងស្រុង ព្រោះជាបណ្តឹងគ្មានការពិតទាល់តែសោះ។ គាត់សំអាងលើលិខិតនេះយកមកប្តឹងខ្ញុំដែលបានលើកឡើងថា ខ្ញុំបានលក់ដីចំហំ ៦ហិកតា ស្ថិតនៅសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យទៅឈ្មោះ[redacted] លីគាង ខ្ញុំមិនបានដឹងថាឈ្មោះ[redacted]លីគាង បានលិខិតនេះមកពីណាឡើយ ម្យ៉ាងទៀតចំពោះលិខិតដែលសរសេរជាភាសាចិន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលឈ្មោះ[redacted] លីគាង អះអាង ថា ខ្ញុំជាអ្នកសរសេរទិញលក់ដីជាមួយគាត់នោះ មិនមែនខ្ញុំជាអ្នកសរសេរឱ្យគាត់ឡើយ ហើយហត្ថលេខាខាងលើលិខិតនោះក៏មិនមែនជាហត្ថលេខារបស់ខ្ញុំដែរ ហើយក្នុងរឿងនេះឈ្មោះ[redacted] លីគាង បានធ្វើការប្តឹងជាច្រើនដងមកហើយទៅលើអង្គហេតុតែមួយ ត្រូវបានតុលាការតម្កល់ទុកឥតចាត់ការអ្វីចមេធាវីរបស់ខ្ញុំបានបញ្ជូលភស្តុតាងក្នុងសំណុំរឿង។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **លីគាង** បានឆ្លើយថា៖ សូមរក្សាចម្លើយរបស់ខ្ញុំនៅដំណាក់កាលអយ្យការដដែល ដោយពុំតែប្រែចំណុចណាមួយឡើយ ខ្ញុំសូមបញ្ជាក់បន្ថែមថា

ខ្ញុំនិងឈ្មោះ [redacted] ហួគង់ ត្រូវជាពូនិងក្មួយនឹងគ្នា។ នៅក្នុងអំឡុងឆ្នាំ១៩៩៨ ឈ្មោះ [redacted] ហួគង់ បានបបួលខ្ញុំជួយទិញដីពីគាត់ដោយសារតែគាត់កំពុងមានបញ្ហារឿងលុយកាក់ផង ទើបបានហៅឱ្យជួយទិញដីនៅក្នុងទីតាំងសង្កាត់បឹតត្រាំង ខណ្ឌព្រែនប់ ខណ្ឌព្រះសីហនុ ដោយគាត់បានធ្វើការអះអាងថា គាត់មានភាគហ៊ុន ហួលីត្រេឌីង ចំនួន១០ ហិកតាកន្លះ។ ស្របពេលជាមួយគ្នានោះដែរដោយសារមានការទុកចិត្តគិតថាជាពូទើបយល់ព្រមទិញដីចំនួន ៣ហិកតា ក្នុងតម្លៃ ៣0.000(បីម៉ឺន) ដុល្លារអាមេរិក និងបានប្រគល់ប្រាក់ឱ្យទៅឈ្មោះ [redacted] ហួគង់ ភ្លាមៗតែម្តង ហើយក៏បានសរសេរជាភាសារចិនឱ្យខ្ញុំដោយសម្គាល់ថាដីនោះបានលក់មកឱ្យខ្ញុំហើយ ដូចមានភស្តុតាងបញ្ជាក់ក្នុងសំណុំរឿង។ សូម្បីតែទីតាំងដីក៏ខ្ញុំមិនដែលស្គាល់ផងដោយភាពទុកចិត្តជាពូ ទើបពុំបានចុះពិនិត្យទីតាំងដីដែលបានទិញរហូរដល់ឆ្នាំ២០១៨ នៅពេលក្រុមហ៊ុន ហួលីត្រេឌីង បានធ្វើការលក់ដីក្នុងក្រុមហ៊ុនឱ្យទៅអ្នកផ្សេង ទើបខ្ញុំដឹងថាឈ្មោះ [redacted] ហួគង់ពុំមានឈ្មោះក្នុងភាគហ៊ុន ប៉ុន្តែបែរជាមានឈ្មោះ [redacted] សុខឡេង ជាប្រពន្ធទី២របស់គាត់ទៅវិញ ឈ្មោះ [redacted] ហួគង់ មានដីមួយកន្លែងទៀត ទល់មុខដីក្រុមហ៊ុន ហួលីត្រេឌីង និងបានលក់កាលពីឆ្នាំ២០១៩ក៏នៅតែមិនដោះស្រាយមកឱ្យខ្ញុំទៀត ព្រមទាំងគេចវេសរហូតមិនទទួលខុសត្រូវឡើយ។

-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុជាវិទ្ធ** បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់កំណត់ហេតុចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមខ្ញុំជាមេធាវីតំណាងឱ្យភាគីខាងដើមបណ្តឹងសូមធ្វើការកត់សម្គាល់ដូចខាងក្រោម ទីមួយពាក់ព័ន្ធជាមួយអង្គហេតុដូចបានលើកឡើងខាងលើខ្ញុំបាទស្នើសុំធ្វើការប្តូរបទចោទពីបទ **ឆបោក** មកបទ **រំលោភលើទំនុកចិត្ត** វិញដោយមូលហេតុថា ពាក់ព័ន្ធនឹងអង្គហេតុដែលមានការទទួលស្គាល់ប្រាក់ដែលកូនក្តីខ្ញុំប្រគល់ឱ្យភាគីជនជាប់ចោទចំនួន៣0,000(បីម៉ឺន) ដុល្លារអាមេរិក នេះគឺជាប្រាក់ដែលភាគីខាងជនជាប់ចោទមានកាតព្វកិច្ចប្រគល់ត្រឡប់មកវិញ ក៏ប៉ុន្តែសួរថាប្រគល់ត្រឡប់នៅពេលណាដោយសារតែជីវភាពកូនក្តីក្រោយមកជនជាប់ចោទបានធ្វើការលក់ដីនេះតម្លៃ ៣0.000 (បីម៉ឺន) ដុល្លារអាមេរិក ក្លាយទៅជាតម្លៃ ១.២00.000 (មួយលានពីរសែន) ដុល្លារអាមេរិក ឯនោះ ដូច្នេះហើយការប្រគល់ត្រឡប់នេះចំនួន ១.២00.000 (មួយលានពីរសែន) ដុល្លារអាមេរិក ដែលជាកាតព្វកិច្ចប្រគល់មកវិញមិនត្រឹមតែប្រាក់ដើមចំនួន៣0.000(បីម៉ឺន)ដុល្លារអាមេរិកនោះទេ។ ម្យ៉ាងវិញទៀតភាគីជនជាប់ចោទបានលក់អស់ហើយ ជនជាប់ចោទមិនព្រមបំពេញកាតព្វកិច្ចរបស់ខ្លួន ហើយគេចវេសមិនព្រមប្រគល់ប្រាក់លក់ដីដែលស្មើនឹង១.២00.000 (មួយលានពីរសែន) ដុល្លារអាមេរិក កូនក្តីរបស់ខ្ញុំនោះទេ។ ដូចការកត់សម្គាល់ខាងលើនេះ ខ្ញុំបានស្នើសុំប្តូរបទចោទ **ឆបោក** មកបទ **រំលោភលើទំនុកចិត្ត** ហើយកូនក្តីទាមទារឱ្យជនជាប់ចោទបង់ប្រាក់ថ្លៃដីដែលគាត់លក់បាន ១.២00.000 (មួយលានពីរសែន) ដុល្លារអាមេរិក មកឱ្យកូនក្តីខ្ញុំវិញ និងសំណងការខូចខាតចំនួន ២.00.000 (ម្ភៃម៉ឺន) ដុល្លារអាមេរិក។

-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ នាងខ្ញុំសូមឯកភាព និងការកត់សម្គាល់របស់សហភាគារបស់ខ្ញុំ។

-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖កាលពីអំឡុងឆ្នាំ១៩៩៨ ឈ្មោះ ខូវ ហួគង់ ដែលត្រូវជាពូបង្កើតរបស់ឈ្មោះ [redacted] លីគាង គាត់បានហៅឈ្មោះ [redacted] លីគាង ឱ្យទិញដីរបស់គាត់ដែលមាននៅក្នុងក្រុមហ៊ុនហួលី ត្រឌឹង ចំនួន ០ពាហិកតា តម្លៃ ៣០០០០(បីម៉ឺន)ដុល្លារអាមេរិក។ ឈ្មោះ [redacted] លីគាង ក៏យល់ព្រមទិញដីនោះដោយពុំបានទៅមើលទីតាំងដី ឬធ្វើឯកសារផ្ទេរសិទ្ធិអ្វីទាំងអស់ដោយមានការជឿជាក់និងទុកចិត្ត និងដោយសំអាងថា ឈ្មោះ [redacted] ហួគង់ ជាពូបង្កើតរបស់ខ្លួនគាត់នឹងមិនកុហក់បោកប្រាស់ ខូវ លីគាង នោះទេ។ នៅពេលឈ្មោះ [redacted] លីគាង បានប្រគល់ប្រាក់ឱ្យទៅ [redacted] ហួគង់ ដែលបញ្ជាក់ថាឈ្មោះ [redacted] ហួគង់ បានលក់ដីឱ្យឈ្មោះ [redacted] លីគាង ចំនួន ពាហិកតា តម្លៃ ៣០០០០(បីម៉ឺន)ដុល្លារអាមេរិក ចាប់ពីថ្ងៃដែលឈ្មោះ [redacted] ហួគង់ លក់ដីឱ្យខ្លួនមកឈ្មោះ [redacted] លីគាង មិនដែលដឹងថា [redacted] ហួគង់ គ្មានដីនៅក្នុងចំណែកភាគហ៊ុននៃក្រុមហ៊ុន ហួលី ត្រឌឹងនោះទេ។ ឈ្មោះ [redacted] លីគាង ទើបតែដឹងនៅពេលក្រុមហ៊ុន ហួលី ត្រឌឹង បានធ្វើការលក់ដីឱ្យទៅអ្នកផ្សេងនៅឆ្នាំ២០១៨ ទើបខ្លួនដឹងថាឈ្មោះ [redacted] ហួគង់ ពុំមានដីនៅក្នុងក្រុមហ៊ុន ហួលី ត្រឌឹង នោះឡើយ ហើយនៅពេលដែលឈ្មោះ [redacted] លីគាង ទាមទារឱ្យឈ្មោះ [redacted] ហួគង់ ប្រគល់ប្រាក់មកវិញតាមតម្លៃទីផ្សារបច្ចុប្បន្នឈ្មោះ [redacted] ហួគង់ គាត់បានឆ្លើយថា គាត់មានដីនៅទល់មុខដីរបស់ក្រុមហ៊ុន ហួលី ត្រឌឹង ហើយនៅពេលដែលគាត់លក់ដីនោះដាច់ហើយគាត់និងធ្វើការដោះស្រាយឱ្យ [redacted] លីគាង វិញតាមតម្លៃទីផ្សារបច្ចុប្បន្ន។ លុះដល់ឆ្នាំ២០១៩ឈ្មោះ [redacted] ហួគង់ ក៏បានលក់ដីដែលគាត់មាននៅទល់មុខដីរបស់ក្រុមហ៊ុនហួលី ត្រឌឹង នោះបាត់បន្ទាប់ពីបានលក់ដីនេះហើយ [redacted] ហួគង់ព្យាយាមគេចវេសពី [redacted] លីគាង រហូតដល់បច្ចុប្បន្ននេះដោយពុំមានដំណោះស្រាយអ្វីជាមួយ [redacted] លីគាង សោះឡើយ។ បន្ទាប់ពី [redacted] លីគាង បានដាក់ពាក្យបណ្តឹងទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ប្តឹងទៅឈ្មោះ [redacted] ហួគង់ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចោទប្រកាន់លើឈ្មោះ [redacted] ហួគង់ ពីបទ ឆបោក តាមរយៈដីកាសន្និដ្ឋានស្តាពរលេខ ៤៤២០ អ.ឃ.ឈ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ហើយបន្ទាប់មកចៅក្រម ស៊ើបសួរនៅសាលាដំបូងរាជធានីភ្នំពេញ ក៏បានចេញដីកាសម្រេចបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ តាមរយៈដីកាសម្រេចបញ្ជូនរឿងមកជំនុំជម្រះលេខ ៥៩៧៤ ដ.ដ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ពីបទ ឆបោក។ ផ្អែកតាមអង្គហេតុបានរៀបរាប់ជូនខាងលើ តើយើងអាចចាត់ទុកថា អំពើរបស់ឈ្មោះ [redacted] ហួងគង់ ជាបទល្មើស **រំលោភលើទំនុកចិត្ត បានដែរ ទេ?** យោងតាមមាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យនៃបទល្មើសរំលោភលើទំនុកចិត្តថា“**អំពើរំលោភលើទំនុកចិត្ត គឺជាអំពើកែបំបាត់មូលនិធិតម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារៈកិច្ចប្រគល់សងវិញបង្ហាញ ឬយកមូលនិធិ

តម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់"។ ចំណែកឯមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ កំណត់ពីទណ្ឌកម្មផងដែរដែលបានបញ្ជាក្តិថា៖អំពើ **រំលោភលើចំនុកចិត្ត** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែទៅ ៣(បី)ឆ្នាំនិងពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ៦.000.000 (ប្រាំមួយលាន)រៀល។ យោងតាមអង្គហេតុខាងលើយើងបានកត់សម្គាល់ឃើញថា៖[redacted] ហួគង់ បានបបួល[redacted] លីគាង ដែលត្រូវជាក្មួយបង្កើតរបស់ខ្លួនឱ្យទិញដីគាត់ដោយគាត់ប្រាប់ថា គាត់មានចំណែកដីរបស់ខ្លួននៅក្នុងក្រុមហ៊ុន ហួលី ត្រឹង ដោយក្នុងលក្ខន្តិក:ក្រុមហ៊ុនបានដាក់ឈ្មោះប្រពន្ធទី២របស់គាត់ជាម្ចាស់ហ៊ុន។ ដោយមានការទុកចិត្តក្នុងនាមជាពូបង្កើត និងក្មួយ[redacted] លីគាង ជឿជាក់ថា[redacted] ហួគង់ នឹងមិនកុហកបោកប្រាស់ខ្លួននោះទេ ទើប[redacted] លីគាង យល់ព្រមប្រគល់ប្រាក់ទិញដីនេះ ដោយពុំបានទៅមើលទីតាំងដី ឬធ្វើឯកសារផ្ទេរសិទ្ធិអ្វីទាំងអស់ ហើយ[redacted] ហួគង់ ក៏បានសរសេរលិខិតមួយសន្លឹកជាអក្សរចិន និងចុះហត្ថលេខារបស់គាត់ប្រគល់ឱ្យឈ្មោះ[redacted] លីគាង ដែលបញ្ជាក់ថាឈ្មោះ [redacted] ហួគង់ បានលក់ដីឱ្យឈ្មោះ[redacted] លីគាង ចំនួន ៣ ហិកតា តម្លៃ ៣0,000 (បីម៉ឺនដុល្លារអាមេរិក)។ បន្ទាប់ពីបានដឹងថាដីនេះបានលក់ក្នុងតម្លៃ ៤00,000 (បួនសែនដុល្លារអាមេរិក) ក្នុងមួយហិកតា កូនក្តីយើងខ្ញុំក៏ទាមទារឱ្យ[redacted] ហួគង់ ប្រគល់ប្រាក់មកវិញឈ្មោះ[redacted] ហួគង់ គាត់ឆ្លើយថាគាត់មានដីនៅទល់មុខដីរបស់ក្រុមហ៊ុន ហួលី ត្រឹង ហើយនៅពេលដែលគាត់លក់ដីនេះដាច់ហើយ គាត់នឹងធ្វើការដោះស្រាយឱ្យ [redacted] លីគាង វិញតាមតម្លៃទីផ្សារបច្ចុប្បន្ន។ លុះដល់ឆ្នាំ២0១៩[redacted] ហួគង់ ក៏បានលក់ដីដែលគាត់មាននៅទល់មុខដីរបស់ក្រុមហ៊ុន ហួលី ត្រឹង នោះបាត់។ បន្ទាប់ពីបានលក់ដីនេះហើយ[redacted] ហួគង់ ព្យាយាមគេសវេសពី[redacted] លីគាង រហូតដល់បច្ចុប្បន្ននេះដោយពុំមានដំណោះស្រាយអ្វីជាមួយ[redacted] លីគាង សោះឡើយ។ បន្ទាប់ពីបានយកប្រាក់ពី[redacted] លីគាង អស់ ៣0000 (បីម៉ឺនដុល្លារអាមេរិក)ម្តងហើយ [redacted] ហួគង់ មិនត្រឹមតែមិនព្រមសងប្រាក់តាមតម្លៃទីផ្សារត្រឡប់ទៅឱ្យ ខ្ញុំវ លីគាង វិញទេ [redacted] ហួគង់ បានកុហក[redacted] លីគាង ម្តងទៀតដោយសន្យាថាគាត់ ([redacted] ហួគង់) នឹងសងប្រាក់ទៅឱ្យ ខ្ញុំវ លីគាង វិញតាមតម្លៃទីផ្សារបច្ចុប្បន្នៅពេលដែលគាត់លក់ដីរបស់គាត់នៅទល់មុខដីរបស់ក្រុមហ៊ុន ហួលី ត្រឹង ដាច់។ លុះដល់ឆ្នាំ ២0១៩ បន្ទាប់ពីបានលក់ដីនេះបាត់ហើយ[redacted] ហួគង់ ព្យាយាមគេសវេសពី[redacted] លីគាង រហូតដល់បច្ចុប្បន្ននេះ ដោយពុំបានសងប្រាក់ទៅ[redacted] លីគាង តាមការសន្យាឡើយ។ យើងខ្ញុំស្នើសុំប្តូរបទចោទពីបទឆបោក ទៅជាបទល្មើសរំលោភលើចំនុកចិត្ត ដោយមូលហេតុថាជាក់ស្តែងគាត់ពិតជាម្ចាស់ដីពិតប្រាកដ ប៉ុន្តែគាត់បានឱ្យ ឈ្មោះ [redacted] សុខឡេង ជាអ្នកឈរឈ្មោះជំនួសក្នុងលក្ខន្តិក:ក្រុមហ៊ុន។ [redacted]ហួគង់ បានប្រព្រឹត្តបទល្មើស រំលោភលើចំនុកចិត្ត ដោយបានកែបំបាត់ប្រាក់របស់ ខ្ញុំវ លីគាង ចំនួន ១,២00,000 (មួយលានពីរសែនដុល្លារអាមេរិក) ដោយយកប្រាក់[redacted] លីគាង ចំនួន ៣0,000 (បីម៉ឺនដុល្លារអាមេរិក) ទៅទិញដីដូចមានបញ្ជាក់ក្នុងលិខិតសរសេរដោយផ្ទាល់ដៃ ហើយគាត់មានកាតព្វកិច្ចប្រគល់ប្រាក់ផ្ទៃលក់ទិញបន្ទាប់ពីលក់ដីបានប៉ុន្តែក្រោយពីលក់ដីបានគាត់ពុំបានសង ហើយព្យាយាមគេចវេសទៅវិញ។ យោងតាមអង្គហេតុ និងអង្គច្បាប់ដូចដែលបានរៀបរាប់ជូនខាងលើ សរបញ្ជាក់ឱ្យឃើញថា អំពើដែល[redacted] ហួគង់ បានប្រព្រឹត្តនាពេលកន្លងមកគឺមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស រំលោភ

ឈើចំនុកចិត្ត។ សំណូមពរ៖ក្នុងនាមឈើងខ្ញុំជាមេធាវីតំណាងដោយអាណត្តិឱ្យ [redacted] លីគាង យើងខ្ញុំសុំឱ្យ តុលាការសម្រេច៖ប្តូរបទចោទពីបទឈ្មើស **ឆបោក** ទៅបទ **រំលោភឈើចំនុកចិត្ត** តាមមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។ ផ្តន្ទាទោសជនជាប់ចោទ ក្នុងកម្រិតអតិបរមាដែលច្បាប់បានកំណត់។ សងប្រាក់ផ្តែលក់ដីតម្លៃ ១.២០០.០០០ (មួយលានពីរសែនដុល្លារអាមេរិក)។ សងសំណងការខូចខាត និងសេវាផ្នែកច្បាប់ ២០០.០០០ (ពីរសែនដុល្លារអាមេរិក)។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងតាមរយៈការសិក្សាសំណុំរឿងនេះ អយ្យការយល់ឃើញថា ចម្លើយ របស់ជនជាប់ចោទដែលបានបញ្ជាក់ថា រឿងនេះត្រូវបានដើមបណ្តឹងប្តឹងច្រើនលើកច្រើនសារមកហើយ ត្រូវបានតំណាងអយ្យការតម្កល់ទុកឥតចាត់ការនោះ មិនមែនជាអាជ្ញារអស់ជំនុំទេ ប្រសិនបើតុលាការ រកឃើញភស្តុតាងថ្មី អាចបើកការស៊ើបសួរនិងបញ្ជូនមកជំនុំជម្រះបាន ហើយពាក់ព័ន្ធនឹងអង្គហេតុនេះ គប្បីលោកស្រីពិចារណាលើលិខិតជាភាសាចិនដែលមានហត្ថលេខារបស់ជនជាប់ចោទធ្វើឡើង ចុះ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលខ្លឹមសារនៃលិខិតនេះបានបញ្ជាក់ពីឈ្មោះ [redacted] ហួគង់ តំណាងក្នុង ការទិញដីឱ្យក្មួយស្រីឈ្មោះ [redacted] លីគាង ចំនួន ៦ហិកតាផ្តើមចេញពីចំណុចនោះហើយនៅដើមឆ្នាំ ២០១៨ មានប្រតិបត្តិការទិញលក់លើដីមានទីតាំងនៅកន្លែងដដែល មានកិច្ចសន្យាជាភស្តុតាងដែលបានដាក់ជូន តុលាការស្រាប់ហើយដុំវិញការទិញលក់ដីនៅក្នុងឆ្នាំ ២០១៨ នេះតំណាងអយ្យការកត់សម្គាល់ឃើញ ថាជាដីដែលមានបញ្ជាក់នៅលិខិតជាភាសាចិន ទោះបីភាគីជាអ្នកលក់បានប្តូរទៅជាក្រុមហ៊ុនហួលី ត្រឹង ក៏ពិតមែន ប៉ុន្តែភាគីក្រុមហ៊ុនជាប្រពន្ធទី ២ របស់ជនជាប់ ចោទជាភាគីជាសាច់ញាតិរបស់ ជនជាប់ចោទ ត្រង់ចំណុចនេះតំណាងអយ្យការយល់គឺការប្រើប្រាស់នូវអំពើទុច្ចរិតលេបយកចំណែក របស់ឈ្មោះ [redacted] លីគាង នេះតាមរយៈការបង្កើតឯកសារជាភាសាចិននេះ ហើយឯកសារជាភាសាចិន នេះបើយើងវាយតម្លៃទៅមានលក្ខណៈគ្រប់គ្រាន់តែម្តង ដែលអាចឱ្យជនជាប់ចោទយកចំណែករបស់ ដើមបណ្តឹងទៅលក់បានយ៉ាងងាយ។ ក្រោយពីបានសិក្សាគឺដំណើរសាច់រឿងដូចដែលខ្ញុំបានលើកឡើង នៅពេលដែលជនជាប់ចោទទទួលលុយចំណែកដីនៅឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០១៨ មិនមានបទ ឈ្មើសកើតឡើងនោះទេ ទើបជនជាប់ចោទបានចំណែកដីរបស់ដើមបណ្តឹងទៅចាត់ចែង ដូចនេះនៅ ក្នុងសំណុំរឿងនេះអង្គហេតុនៃបទឈ្មើសកើតនៅឆ្នាំ ២០១៨ ពេលដែលលក់ដីបានរហូតដល់ ១.២០០.០០០ (មួយលានពីរសែន) ដុល្លារអាមេរិក ហើយជនជាប់ចោទបានគេចវេសរហូតដល់សព្វថ្ងៃទើបមានការ ប្តឹងផ្តល់គ្នារហូតដល់បច្ចុប្បន្ននេះ។ នៅពេលដែលជនចាប់ចោទយកចំណែកដីរបស់អ្នកដទៃទៅ ធ្វើចាត់ចែងជាកំណត់ជាធាតុផ្សំបទឈ្មើស **រំលោភឈើចំនុកចិត្ត** ដូចនេះតំណាងអយ្យការស្នើសុំប្តូរ បទចោទពីបទ **ឆបោក** មកបទឈ្មើស **រំលោភឈើចំនុកចិត្ត** តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងសូមចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖

ខ្ញុំសូមបដិសេធចំពោះការអះអាងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងអយ្យការកូនក្តី
របស់ខ្ញុំបាទមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ បើពិនិត្យលើសំណុំរឿងនេះឃើញថាដើមបណ្តឹង
បានប្រឌិតរឿង និងការឡែអង្គហេតុ ធ្វើការប្តឹងចំណុចដដែលៗ និងអង្គហេតុតែមួយ កាលពីថ្ងៃទី២៩
ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] លីគាង បានធ្វើការប្តឹងកូនក្តីខ្ញុំម្តងរួចហើយនៅការិយាល័យព្រហ្មទណ្ឌ
កងរាជអាវុធហត្ថរាជធានីភ្នំពេញ បញ្ជូនមកតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
ហើយត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ២៨១៥ អ.យ.ក ចុះថ្ងៃទី
២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ហើយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ
[redacted]លីគាង បានប្តឹងតវ៉ានឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការហើយត្រូវបានមហាអយ្យការអម
សាលាឧទ្ធរណ៍សម្រេចតម្កល់ដីកាសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញលេខ ០១៧ ស.ត.ប្រក.០២០
ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ មានន័យថា កូនក្តីខ្ញុំពុំមានពិរុទ្ធភាពដូចការចោទប្រកាន់បទល្មើស
នេះទេ ខ្ញុំបាទសូមបញ្ជាក់ថា ឈ្មោះ [redacted] លីគាង បានប្តឹងកូនក្តីខ្ញុំម្តងរួចហើយទាំងបទល្មើសនិងអង្គ
ហេតុតែមួយ ជាគោលការណ៍ច្បាប់មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ ជនណាដែល
តុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ មិនអាចចោទប្រកាន់បានទេចំពោះអំពើដដែលក្រោម
ការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ។បើពិនិត្យទៅលើអង្គហេតុឃើញថា រឿងនេះកើតឡើងតាំង
តែពីឆ្នាំ១៩៩៨រហូតមកដល់បច្ចុប្បន្នគិតមានរយៈពេលប្រហែល ២០ឆ្នាំជាងមកហើយហួសរយៈពេល
ផុតអាជ្ញាយុកាលនៃការប្តឹង មានន័យថាផុតអាជ្ញាយុកាលនៃការប្តឹងផ្អែកតាមមាត្រា១០ នៃក្រម
នីតិវិធី។ ម្យ៉ាងវិញទៀតនៅដំណាក់កាលអយ្យការកោះហៅកូនក្តីខ្ញុំមិនបានដឹងនោះទេ ហើយកូនក្តី
ខ្ញុំមិនបានទទួលដំណឹងទាល់តែសោះ សរុបមកតាមការស៊ើបអង្កេត និងសិក្សាលើសំណុំរឿងឃើញ
ថា វិមតិសង្ស័យយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌវិមតិ
សង្ស័យបានជាប្រយោជន៍របស់ជនជាប់ចោទ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឈ្មោះ [redacted] ហ្វគង់ រួចផុតពីបទអបោកតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារតប
ថា៖ ការលើកឡើងរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទរឿងអាជ្ញាអស់ជំនុំក្នុងមាត្រា ៤១ នៃក្រម
នីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា អាជ្ញាអស់ជំនុំ រឿងតម្កល់រឿងទុកឥតចាត់ការមិនមែនជា
អាជ្ញាអស់ជំនុំទេ ឱ្យតែមានភស្តុតាងថ្មីតុលាការចោទប្រកាន់បាន។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលោក [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖
អង្គហេតុតាំងតែពីឆ្នាំ១៩៩៨ ទាក់ទងនឹងការប្តឹងផ្តល់សូមលោកស្រីចៅក្រមមេត្តាពិចារណា។

-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារតប
ថា៖ពាក់ព័ន្ធនឹងអាជ្ញាយុកាល ទាក់ទិនក្នុងការទិញលក់ដីនៅក្នុងឆ្នាំ២០១៨ គាត់ឱ្យលុយដោយមានការ
ជឿទុកចិត្ត ប៉ុន្តែបទល្មើសកើតឡើងនៅឆ្នាំ២០១៨ អាជ្ញាយុកាលមិនទាន់ផុតរលត់នៅឡើយទេ

បទល្មើសកើតឡើងនៅពេលដែលគាត់យកភាគហ៊ុនក្រុមហ៊ុនលក់ទៅឱ្យតតិយជននៅក្នុងឆ្នាំ២០១៨ ជាអង្គហេតុដែលកើតឡើង។

-ជនជាប់ចោទឈ្មោះ [redacted] ហួគង់ បាននិយាយសំម្តីចុងក្រោយបង្អស់ថា៖ គ្មាន

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហួគង់

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីគាង

-ក្រោយពីបានស្តាប់អំណានសេចក្តីសន្និដ្ឋានមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៤៣ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០ តាមដីកាសម្រេចបញ្ជូនរឿងមកជំនុំជម្រះលេខ ៥៩៧៤ "ដ"ដ.ដ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ហួគង់ ភេទប្រុស ពីបទ **ឆបោក** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ឈ្មោះ [redacted] លីគាង បានដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ប្តឹងឈ្មោះ [redacted] ហួគង់ ពីបទ ឆបោក។ ឈ្មោះ [redacted] លីគាង បានអះអាងថា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ឈ្មោះ [redacted] ហួគង់ បានហៅខ្លួនឱ្យទិញដីរបស់គាត់ក្នុងភាគហ៊ុនក្នុងក្រុមហ៊ុន ហួលី ត្រឹមចំនួន ៣ហិកតា ក្នុងតម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ខ្លួនក៏បានយល់ព្រមទិញដីនេះ ដោយមិនបានមើលទីតាំងដី ឬធ្វើឯកសារផ្ទេរកម្មសិទ្ធិអ្វីទាំងអស់ដោយសំអាងថា គាត់ជាពូបង្កើតមិនកុហកបោកប្រាស់ ហើយខ្លួនក៏បានប្រគល់ប្រាក់ទៅឱ្យឈ្មោះ [redacted] ហួគង់ ដោយគាត់សរសេរលិខិតមួយសន្លឹកជាអក្សរចិន និងបានចុះហត្ថលេខារបស់គាត់ប្រគល់ឱ្យមកខ្លួន បញ្ជាក់ថាគាត់លក់ដីឱ្យខ្លួនចំនួន ៣ហិកតា ក្នុងតម្លៃ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក និងលក់ឱ្យទៅបងស្រីឈ្មោះ Iven ចំនួន ៣ហិកតា ហើយនិងលក់ឱ្យឈ្មោះ [redacted]ជូ ចំនួន ៣ហិកតា សរុបចំនួន ៩ហិកតា។ នៅក្នុងឆ្នាំ២០១៨ ខ្លួនបានដឹងថាឈ្មោះ [redacted] ហួគង់ គ្មានដីក្នុងចំណែកភាគហ៊ុន ហួលីត្រឹមទេ ខ្លួនបានស្នើសុំឱ្យឈ្មោះខូវ ហួគង់ សងប្រាក់ថ្លៃដីតាមតម្លៃទីផ្សារដែលមានទីតាំងស្ថិតនៅភូមិបិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ មកវិញតែគាត់ពុំព្រមគេចវេសរហូត។

៣-ជនជាប់ចោទឈ្មោះ [redacted] ហួងគង់ បានឆ្លើយថា៖ ខ្លួនសូមបដិសេធចំពោះការចោទប្រកាន់ និងពាក្យបណ្តឹងរបស់ឈ្មោះ [redacted] លីគាង ចោលទាំងស្រុង ព្រោះជាបណ្តឹងគ្មានការពិតគាត់យកលិខិតដែលសរសេរជាភាសាចិន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលឈ្មោះ [redacted] លីគាង អះអាងថាខ្លួន

ជាអ្នកសរសេរទិញលក់ដីជាមួយគាត់នោះ មិនមែនខ្លួនជាអ្នកសរសេរឱ្យគាត់ឡើយ ហើយហត្ថលេខាលើលិខិតនោះក៏មិនមែនជាហត្ថលេខារបស់ខ្លួនដែរ។ ឈ្មោះខូវលីគាងបានធ្វើការប្តឹងជាច្រើនដងមក ហើយទៅលើអង្គហេតុតែមួយ ត្រូវបានតុលាការតម្កល់ទុកឥតចាត់ការដូចមេធាវីរបស់ខ្លួនបានបញ្ជូលភស្តុតាងក្នុងសំណុំរឿង។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] លីគាង បានឆ្លើយថា៖ នៅក្នុងអំឡុងឆ្នាំ១៩៩៨ ឈ្មោះ[redacted] ហួគង់ បានបបួលខ្លួនឱ្យជួយទិញដីពីគាត់នៅសង្កាត់តាំងបិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ ដោយគាត់បានអះអាងថា មានភាគហ៊ុន ហួលីត្រឹង ចំនួន១០ ហិកតាកន្លះ ដោយមានការទុកចិត្តគិតថាជាពូទើបយល់ព្រមទិញដីចំនួន ៣ហិកតា ក្នុងតម្លៃ ៣០.០០០ (បីម៉ឺន)ដុល្លារអាមេរិក និងបានប្រគល់ប្រាក់ឱ្យទៅគាត់ភ្លាមៗតែម្តង ហើយគាត់បានសរសេរជាភាសាចិនឱ្យខ្លួនដោយសម្គាល់ថា ដីនោះបានលក់មកឱ្យខ្លួន។ នៅឆ្នាំ២០១៨ ក្រុមហ៊ុន ហួលីត្រឹង បានលក់ដីក្នុងក្រុមហ៊ុនឱ្យទៅអ្នកផ្សេង ទើបខ្លួនដឹងថាឈ្មោះ[redacted]ហួគង់ពុំមានឈ្មោះក្នុងភាគហ៊ុន ប៉ុន្តែបែរជាមានឈ្មោះ[redacted] សុខឡេង ជាប្រពន្ធទី២របស់គាត់ទៅវិញ ឈ្មោះ [redacted] ហួគង់ មានដីមួយកន្លែងទៀតទល់មុខដីក្រុមហ៊ុន ហួលីត្រឹង និងបានលក់កាលពីឆ្នាំ២០១៩ក៏នៅតែមិនដោះស្រាយមកឱ្យខ្លួនទៀតព្រមទាំងគេចវេសរហូតមិនទទួលខុសត្រូវឡើយ។

៥-តាមការពិនិត្យពាក្យបណ្តឹង និងចម្លើយរបស់ដើមបណ្តឹងនៅដំណាក់កាលអយ្យការក៏ដូចជានៅដំណាក់កាលចៅក្រមស៊ើបសួរឃើញថា៖ឈ្មោះ[redacted]លីគាងប្តឹងឈ្មោះ[redacted] ហួគង់ ពីបទ ឆបោក ដោយសំអាងទៅលិខិតសរសេរជាអក្សរចិន ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដោយបានបកប្រែជាភាសាខ្មែរ

៦-ផ្អែកតាមការពិនិត្យភស្តុតាងជាភាសាខ្មែរ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលបានបកប្រែពីលិខិតសរសេរជាអក្សរចិនមានខ្លឹមសារថា៖ ខ្ញុំបាទឈ្មោះ[redacted] ហួគង់ ជាឪពុកមាតុចបានទិញដីនៅក្រុងព្រះសីហនុ ដែលជាដីរបស់ក្រុមហ៊ុន ហួលី ចំនួន ៦៧ហិកតា ក្បួយស្រី[redacted] លីគាង ចំនួន ៦ហិកតា ហើយលោកស្រី Iven ចំនួន ៣ហិកតាបន្ថែមទៀត ដូច្នេះផ្ទៃដីសរុបមានចំនួន ៩០.០០០ម៉ែត្រការ៉េ ទទួលបានជាភស្តុតាង។ ក្នុងខ្លឹមសារនៃលិខិតនេះស្តែងឱ្យឃើញថា អង្គហេតុដែលដើមបណ្តឹងប្តឹងជនជាប់ចោទគឺផ្ទុយពីភស្តុតាងដែល ដើមបណ្តឹងបានអះអាងថា ខ្លួនទិញដីពីឈ្មោះ[redacted] ហួគង់ ចំនួន ០៣ហិកតា រីឯក្នុងភស្តុតាងលិខិតសរសេរជាអក្សរចិន និងបានបកប្រែជាភាសាខ្មែរ គឺចំនួនរហូតដល់ ៦ហិកតា ឯណោះ។ នៅក្នុងលិខិតដដែលនេះ ក៏មិនបានបញ្ជាក់អំពីទីតាំងដីស្ថិតនៅភូមិ-ឃុំណាឱ្យពិតប្រាកដនោះទេ គ្រាន់តែបញ្ជាក់ថា នៅខេត្តព្រះសីហនុ តែប៉ុណ្ណោះ មិនដូចការអះអាងរបស់របស់ដើមបណ្តឹងថាដីដែលខ្លួនទិញពីឈ្មោះ[redacted] ហួគង់ស្ថិតនៅក្នុងសង្កាត់បឹងត្រាំង ខណ្ឌព្រៃនប់នោះឡើយ។ តុលាការយល់ឃើញថា លិខិតនេះមិនមានភាពច្បាស់លាស់ដែលអាចកំណត់ថាជាកិច្ចសន្យាទិញលក់ដីនោះទេ។

៧-ឈ្មោះ[redacted]លីគាង បានអះអាងថា៖ ជនជាប់ចោទឈ្មោះ[redacted] ហួគង់ បានប្រាប់ខ្លួនថា គាត់មានភាគហ៊ុននៅក្នុងក្រុមហ៊ុនហួលីត្រឹង ការអះអាងនេះពុំមានសាក្សី ឬភស្តុតាងណាយកមកបញ្ជាក់ឱ្យតុលាការជឿបាននោះទេ ហើយលិខិតទិញលក់ដីក៏ដើមបណ្តឹងគ្មានដែរ។

៨-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារដោយបានស្នើសុំឱ្យតុលាការសម្រេចកែប្រែបទចោទពីបទ **ឆបោក** មកបទល្មើស **រំលោភលើចំនុកចិត្ត** តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ វិញនោះ តុលាការយល់ឃើញថា ពុំមានភាពត្រឹមត្រូវនោះទេ។

៩-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាន នាពេលសវនាការដោយបានប្តឹងសុំចៅក្រមជំនុំជម្រះសម្រេចកែប្រែបទចោទពីបទ **ឆបោក** មកបទល្មើស **រំលោភលើចំនុកចិត្ត** និងបានលើកឡើងពីភស្តុតាងនានាបញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **ហួគង់** ពីបទ **រំលោភលើចំនុកចិត្ត** តុលាការយល់ឃើញថា ពុំមានភាពត្រឹមត្រូវនោះទេ។

១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារដោយបានស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ គប្បីតុលាការលើកយកមកពិចារណាដូចការយល់ឃើញខាងលើ

១១-ពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **ហួគង់** **អាទប្រុស** ពីបទ **ឆបោក** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌឡើយ គប្បីឱ្យជនជាប់ចោទឈ្មោះ ខូវ ហួគង់ រួចផុតពីបទ ឆបោក តាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះសម្រេច

១-ឱ្យឈ្មោះ [redacted] **ហួគង់** **អាទប្រុស** **អាយុ** ៦៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ពាណិជ្ជករ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ធំ មានទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះលេខ ១A ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ឡាក់"ស" ម្តាយឈ្មោះ [redacted] ឯនខេង "ស" ប្រពន្ធឈ្មោះ [redacted] សុខឡេង (ឡែងលះ)មានកូនចំនួន ០២នាក់ ជានីតិជន **ទោសពីមុនគ្មាន**។

រួចផុតពីបទ ឆបោក ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី**២៤** ខែ**កុម្ភៈ** ឆ្នាំ**២០២២** និងប្រកាសជាសាធារណៈនៅថ្ងៃទី**០៩** ខែ **មីនា** ឆ្នាំ **២០២២** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ហួគង់** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា

[redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៧រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]